**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
******

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
******

នៅរសៀលថ្ងៃទី០៧ ខែឧសភា ឆ្នាំ ២០១៩ នៅទីស្តីការក្រសួង **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានទទួលជួបពិភាក្សាការងារជាមួយលោកស្រីសាស្ត្រាចារ្យ **រ៉ូណា ស្មីត** (Rhona Smith) អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះដំណើរបំពេញទស្សនកិច្ចការងាររបស់លោកស្រីជាលើកទី៧ នៅកម្ពុជា។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានជម្រាបជូនពីការវិវត្តគួរកត់សម្គាល់ជាច្រើន ពាក់ព័ន្ធនឹងការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងលំហរនយោបាយនៅកម្ពុជា។ ទន្ទឹមនេះ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានជម្រាបលោកស្រី **រ៉ូណា ស្មីត** អំពីជំនួបរវាង **សម្តេចតេជោ នាយករដ្ឋមន្ត្រី** និងបណ្តាភ្នាក់ងារអង្គការសហប្រជាជាតិ (UN Team) ប្រចាំកម្ពុជា កាលពីថ្ងៃទី០៦ ខែឧសភា ដែលក្នុងឱកាសនោះ លោកស្រី Pauline Tamesis បានកោតសរសើរពីសមិទ្ធផលដែលកម្ពុជាសម្រេចបាន ជាពិសេសពីវឌ្ឍនភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ហើយបានលើកទឹកចិត្តឱ្យមានតំណាងកម្ពុជា ធ្វើបទបង្ហាញពីសមិទ្ធផលទាំងនេះ នៅក្នុងសម័យប្រជុំនៃវេទិកានយោបាយកម្រិតខ្ពស់ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព នាខែកក្កដាខាងមុខនេះ នៅទីក្រុងញូវយ៉ក។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ឡើងវិញថា រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តខិតខំបំពេញការងាររបស់ខ្លួនទៅតាមទិសដៅនេះ។

ជាការឆ្លើយតប លោកស្រី **រ៉ូណា ស្មីត** យល់ស្របថា កម្ពុជាពិតជាមានការវិវត្តរីកចម្រើនមែន។ លោកស្រីលើកទឹកចិត្តឱ្យមានការធ្វើបទបង្ហាញរបស់កម្ពុជានៅទីក្រុងញូវយ៉កនាខែកក្កដាខាងមុខនេះ។ វានឹងមិនត្រឹមតែជាឱកាសល្អ ដែលកម្ពុជាបង្ហាញពីសមិទ្ធផលរបស់ខ្លួននោះទេ តែក៏អាចចែករំលែកបទពិសោធន៍ជោគជ័យនៃការអភិវឌ្ឍរបស់ខ្លួន ទៅកាន់បណ្តាប្រទេសផ្សេងផងដែរ។ ពេលគឺលោកស្រីបានកត់សម្គាល់ឃើញ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល មានចំណុចដៅលំអិតច្រើន ដែលមិនឃើញចែងនៅក្នុងសូចនាករនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ។

លោកស្រី **រ៉ូណា ស្មីត** ក៏បានកោតសរសើរចំពោះកម្ពុជា ដែលបានផ្តល់សច្ចាប័នលើសន្ធិសញ្ញានានាទាក់ទងនឹងសិទ្ធិមនុស្សច្រើនជាងគេ បើប្រៀបធៀបជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ាន។ លោកស្រី បានបញ្ជាក់ថា ព័ត៌មានដែលលោកស្រីទទួលបានពីគ្រប់ភាគីពាក់ព័ន្ធក្នុងអំឡុងពេលទស្សនកិច្ច

ការងារនេះ នឹងយកទៅរៀបចំសរសេរជារបាយការណ៍ ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ នៅខែកញ្ញាខាងមុខនេះ។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានអរគុណចំពោះយោបល់ស្ថាបនានានារបស់លោកស្រី **រ៉ូណា ស្មីត** ហើយបានបង្ហាញក្តីរំពឹងថា របាយការណ៍របស់លោកស្រី ដែលនឹងចេញផ្សាយនាពេលខាងមុខ នឹងផ្អែកលើតថភាពនៃការរីកចម្រើនពិតប្រាកដ និងស្នើថាការវាយតម្លៃពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ត្រូវផ្អែកលើប្រវត្តិសាស្ត្រនិងលក្ខណៈពិសេសរបស់សង្គមខ្មែរ។

ជារួម **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** និងលោកស្រី **រ៉ូណា ស្មីត** បានលើកឡើងចំណុចវិជ្ជមានជាច្រើនទាក់ទងនឹងវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍជាតិ និងការលើកតម្កើងសិទ្ធិមនុស្សនៅកម្ពុជា ដែលទាមទារឱ្យមានការចូលរួមពីគ្រប់ភាគី និងក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់៕

ថ្ងៃ ពុធ ៥កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២

ភ្នំពេញ ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ២០១៩